អាយុ៩-១១ឆ្នាំ

# ព្រះគម្ពីរសម្រាប់កុមារ
# មើលតាមរូបភាព





សញ្ញាចាស់២

សៀវភៅអនុវត្ត



KIDS GOD WORSHIP
www.kidsworship.kr
Selah
Ministry of Christian Publishing

# ព្រះគម្ពីរសម្រាប់កុមារមើលតាមរូបភាព

## សៀវភៅអនុវត្ត សញ្ញាចាស់២

### អាយុ៩-១១ឆ្នាំ

កែសម្រួល kidsworship Selah

បកប្រែដោយ | KOMA Cambodia រចនាក្រាហ្វិក | Jeewon Park, Julio Blas ការកែសម្រួល | KOMA Cambodia

ហាមថតចម្លងទាំងស្រុង ឬផ្នែកណាមួយនៃសៀវភៅនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ

# លិបិក្រម


១. យ៉ាកុប ៣ ............ 6

២. យ៉ូសែប ១ ............ 9

៣. យ៉ូសែប ២ ............ 13

៤. ម៉ូសេ ១ ............ 17

៥. ម៉ូសេ ២ ............ 21

៦. ម៉ូសេ ៣ ............ 25

៧. យ៉ូស្វេ ............ 29

៨. គេឌាន និងទ័ពបីរយនាក់ ............ 33

៩. សាំសុន ............ 37

១០. នាងរស់ កូនប្រសារដ៏ស្មោះត្រង់ ............ 42

# ចូរកត់ត្រាអំពីដំណើរនៃសកម្មភាព។

ចូរផាត់ពណ៌ បន្ទាប់ពីបញ្ចប់រឿងនីមួយៗ។

ស្កេន QR
ដើម្បីចូលទៅស្ដាប់រឿង។



## រឿងទី១៖ យ៉ាកុប ៣

**ខគម្ពីរ៖ លោកុប្បត្តិ៣៣៖១០**

ពេលខ្ញុំឃើញមុខលោកបង ក៏ដូចជាបានឃើញព្រះភ័ក្ត្រព្រះជាម្ចាស់ដូច្នោះដែរ ព្រោះលោកបងបានទទួលខ្ញុំយ៉ាងរាក់ទាក់។

ម្ភៃឆ្នាំបានកន្លងទៅ យ៉ាកុបមានការនឹករលឹកដល់ស្រុកកំណើតដែលខ្លួនបានចេញមកនោះជាខ្លាំង។
មានថ្ងៃមួយ យ៉ាកុបបាននាំហ្វូងសត្វ ព្រមទាំងទ្រព្យសម្បត្តិដែលគាត់រកបានទាំងប៉ុន្មានធ្វើដំណើរចាកចេញទៅទឹកដីកាណានជាស្រុកកំណើតគាត់។
ពេលទៅកាន់តែជិតដល់ផ្ទះ យ៉ាកុបកាន់តែព្រួយបារម្ភ ព្រោះគាត់ខ្លាចអេសាវជាបងគាត់នោះណាស់។
យ៉ាកុបបានបញ្ជូនបាវបម្រើរបស់គាត់ឱ្យទៅជួបអេសាវមុន។
បន្តិចក្រោយមក ពួកអ្នកបម្រើក៏ត្រឡប់មកវិញ និយាយប្រាប់យ៉ាកុបថា៖ «បងប្រុសលោកម្ចាស់កំពុងនាំមនុស្សបួនរយនាក់មកជួបលោកម្ចាស់»។
ឮអ្វីដែលបាវបម្រើនិយាយហើយ យ៉ាកុបភិតភ័យយ៉ាងខ្លាំង ព្រោះគិតថាអេសាវជាបងមកវាយប្រហារខ្លួន។
យ៉ាកុបបានបញ្ជូនគ្រួសារទាំងអស់ទៅមុន ហើយបង្គាប់ឱ្យបាវបម្រើត្រៀមរៀបចំជំនូនសម្រាប់ជូនបងប្រុស។
យ៉ាកុបគិតថាអេសាវជាបងនោះអាចនឹងវាយប្រហារគាត់ ដូច្នេះគាត់មិនអាចទៅជាមួយពួកគេបានទេ។
នៅយប់នោះ យ៉ាកុបអង្គុយពិបាកចិត្តម្នាក់ឯង។ ប៉ុន្តែ ស្រាប់តែមានមនុស្សម្នាក់លេចចេញមក។
មនុស្សម្នាក់នោះគឺជាទេវតាដែលព្រះជាម្ចាស់បញ្ជូនមក។ យ៉ាកុបបានបោកចំបាប់ជាមួយទេវតានោះពេញមួយយប់។
ព្រោះតែមិនចង់ចាញ់ យ៉ាកុបខំស៊ូទ្រាំជាខ្លាំង។
រហូតដល់ព្រះអាទិត្យរះឡើង ទេវតានោះក៏និយាយថា៖ «ចាប់ពីពេលនេះទៅ ឈ្មោះឯងនឹងត្រូវហៅថា អ៊ីស្រាអែលវិញ»។
ទេវតានោះបានចាកចេញទៅ ហើយយ៉ាកុបក៏បានទៅជួបអេសាវជាបង។
ផ្ទុយពីការព្រួយបារម្ភរបស់យ៉ាកុប អេសាវបែរជារីករាយរត់មកទទួលយ៉ាកុបជាប្អូនយ៉ាងកក់ក្តៅ។
បងប្អូនទាំងពីរនាក់នេះ ខានជួបគ្នាអស់រយៈពេលយ៉ាងយូរ ដូច្នេះពួកគេឱបគ្នាទៅវិញទៅមកដោយក្តីរីករាយ។
យ៉ាកុបដែលឱ្យតម្លៃខ្ពស់ទៅលើព្រះពររបស់ព្រះជាម្ចាស់ និងពររបស់ឪពុកម្តាយ បានក្លាយជាអ្នកមានទ្រព្យសម្បត្តិ
ដោយសារព្រះជាម្ចាស់បានជួយគាត់ ហើយគាត់បានត្រឡប់ទៅស្រុកកំណើតវិញ។





**សកម្មភាពទី១** សូមឆ្លើយសំណួរខាងក្រោម។

a. ហេតុអ្វីបានជាយ៉ាកុបបញ្ជូនក្រុមគ្រួសាររបស់គាត់ទៅមុន ហើយប្រាប់ឱ្យអ្នកបម្រើរៀបចំអំណោយសម្រាប់បងប្រុសរបស់គាត់?

---

b. តើយ៉ាកុបបានទទួលឈ្មោះអ្វី បន្ទាប់ពីចំបាប់ជាមួយនឹងទេវតា?

---

c. សូមអានលោកុប្បត្តិ៣៣៖១-១១ រួចឆ្លើយសំណួរ។ តើអេសាវមានប្រតិកម្មបែបណា ក្រោយពេលជួបយ៉ាកុបប្អូនប្រុសរបស់គាត់??

---

d. តើអ្នករៀនបានអ្វីខ្លះពីរឿងនេះ?

---

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (លោកុប្បត្តិ ៣៣៖១០)

> ពេលខ្ញុំឃើញមុខលោកបង ក៏ដូចជាបានឃើញព្រះភ័ក្ត្រព្រះជាម្ចាស់ដូច្នោះដែរ ព្រោះលោកបងបានទទួលខ្ញុំយ៉ាងរាក់ទាក់។

**សកម្មភាពទី២** សូមជួយយ៉ាកុបឱ្យត្រឡប់មកស្រុកកាណានវិញ។

